# ការណែនាំរបៀបរៀបចំខ្លួនដើម្បី
# ធ្វើបារីយ៉ូម អេនីម៉ាតែស្ត

ថ្ងៃណាត់ជួប : ______________________
ម៉ោងណាត់ជួប : ______________________
ទីកន្លែង : ______________________

វេជ្ជបណ្ឌិតបានសុំឲ្យលាងពោះវៀនធំរបស់អ្នក ដោយការបញ្ចូលទឹកបារីយ៉ូមអេនីម៉ា ។ ជាការសំខាន់ណាស់ដែលអ្នកចាំបាច់ត្រូវតែសម្អាតពោះវៀនធំរបស់អ្នកដោយធ្វើឲ្យវាទទេស្អាត ដើម្បីអោយគ្រូពេទ្យពិនិត្យមើលបានឃើញច្បាស់ ។ ដោយហេតុនេះហើយ អ្នកត្រូវអនុវត្តតាមការណែនាំរបៀបបញ្ចូលទឹកបារីយ៉ូមអេនីម៉ានេះ ដោយក្តីប្រយ័ត្ន ។ អ្នកគួរតែបានទទួលការណែនាំនេះ ពីគ្រូពេទ្យរបស់អ្នក ឬ ពីមន្ទីរពិនិត្យរោគដែលអ្នកនឹងទៅពិនិត្យនោះ ។

បើលោកអ្នកមានជម្ងឺក្រលៀនដ៏ធ្ងន់ធ្ងរ ចុកពោះ រាគ ចេញឈាមតាមពោះវៀន ឬក៏ជម្ងឺរលាកពោះវៀនធំ សូមពិភាក្សាជាមួយគ្រូពេទ្យរបស់អ្នកមុននឹងចាប់ផ្តើមធ្វើការបញ្ចូលទឹកបារីយ៉ូមអេនីម៉ា ។ បើលោកអ្នកមិនអាចពិភាក្សាជាមួយគ្រូពេទ្យរបស់អ្នកបានទេ សូមទូរស័ព្ទទៅក្រសួងថតដោយប្រើកាំរស្មីអ៊ិក្ស (X-Ray) ដើម្បីសុំការណែនាំ ។ ទូរស័ព្ទលេខ : ______________________

**១. រយៈពេលពីរថ្ងៃមុនថ្ងៃណាត់ជួប(ថ្ងៃ ខែ ឆ្នាំ) :** ______________________

ក) សូមទទួលទានអាហារណាដែលរាវថ្លាតែប៉ុណ្ណោះ ដូចជា ទឹកស៊ុប ទឹកផ្លែឈើ តែ កាហ្វេ ទឹកក្រូចសូដា ចាហួយ (ចាហួយដែលមិនមានព៌ណក្រហម) ។ សូមកុំពិសារអាហាររឹង ឬទឹកដោះគោឲ្យសោះ ។

**២. រយៈពេលមួយថ្ងៃមុនថ្ងៃណាត់ជួប :** ______________________

ក) ម៉ោង ១:០០ ៣:០០ ៧:០០ ១០:០០ល្ងាច និងនៅពេលចូលដំណេក សូមពិសារទឹកអោយបាន ៨អោនស៍ (១កែវ) បន្ថែមទៀត ។

ខ) ម៉ោង ៥:០០ល្ងាច សូមពិសារទឹក ម៉ែហ្គនីហ្ស៊្យាមសៃត្រេត(ត្រជាក់) មួយដបចំណុះ ៨អោនស៍ ។

គ) ម៉ោង ៨:០០ល្ងាច សូមលេប ថ្នាំឌុលកូឡាក់ ៤គ្រាប់ជាមួយទឹក ៨អោនស៍ ។

**៣. នៅថ្ងៃណាត់ជួប :** ______________________

ក) សូមពិសារ ទឹកក្រូចច្របាច់ ទឹកតែ ឬកាហ្វេ យ៉ាងហោចណាស់អោយបាន ៨អោនស៍ ប៉ុន្តែកុំពិសារអាហារពេលព្រឹកផ្សេងទៀត ។ **កត់សំគាល់:** បើមានការណាត់ជួបធ្វើការពិនិត្យ អិកក្រេតូរី យ៉ូរ៉ូក្រាម ឬ អាយវីភី (Excretory Urogram or IVP) នៅថ្ងៃតែមួយ និងការបញ្ចូលទឹកបារីយ៉ូមអេនីម៉ា សូមកុំពិសារទឹកដូចជំរាបខាងលើទាំងនេះ ដែលមានចំណុះ ៨អោនស៍ ។

ខ) យ៉ាងហោចណាស់រយៈពេល១ម៉ោង មុនពេលចូលពិនិត្យនោះ សូមបញ្ចូលថ្នាំ ឌុលកូឡាក់(Dulcolax suppository) តាមរន្ធគូថរបស់អ្នក ។ ហើយត្រូវរង់ចាំយ៉ាងហោចណាស់ ១៥នាទី មុនពេលបទជើងធំ ។

ក្នុងរយៈពេលធ្វើការពិនិត្យនោះ អ្នកនឹងមានអារម្មណ៏ដូចជា ឆ្អល់ រមួលពោះ ពីតិចទៅខ្លាំង ចង់ទៅបទជើងធំជាបន្ទាន់ ហើយមានអារម្មណ៏ខ្លះដូចជាមិនស្រួលសោះ ។ ចំពោះការថតដោយប្រើកាំរស្មីអ៊ិក្ស (X-Ray) គឺគ្មានឈឺចាប់អ្វីទេ ។

៤. ពេលវេលានិងថ្ងៃខែ ខាងលើគឺបានរៀបចំសំរាប់តែអ្នកប៉ុណ្ណោះ ហេតុដូច្នេះសូមមេត្តាធ្វើយ៉ាងណា រក្សាការណាត់ ឲ្យបានតាមការកំណត់ ។

៥. សូមទូរស័ព្ទទៅខាងក្រសួងថតដោយប្រើកាំរស្មីអ៊ិក្ស (X-Ray) ឬ គ្រូពេទ្យរបស់អ្នក បើអ្នកមិនអាចមកតាមការណាត់ជួបបាន ឬមានសំនួរអ្វី (ទូរស័ព្ទលេខ): ______________________

៦. ក្រោយពីធ្វើការពិនិត្យរួច បើមានការទល់លាមក សូមពិភាក្សាជាមួយគ្រូពេទ្យដើម្បីបញ្ចុះបារីយ៉ូមអេនីម៉ា ចេញពីពោះវៀនធំ ។

Text (**Ethnomed** –http://ethnomed.org) Funded by a grant from the National Cancer Institute through the Asian American Network for Cancer Awareness Research and Training (AANCART); This work is licensed under the Creative Commons Attribution-NonCommercial-NoDerivs License http://creativecommons.org/licenses/by-nc-nd/2.5/

A **Healthy Roads Media** project www.healthyroadsmedia.org